# វ៉ាក់សាំង Novavax សម្រាប់ជំងឺ COVID-19៖ អ្វីដែលអ្នកគួរដឹង

Vaccinate WA
CovidVaccineWA.org

## តើអ្វីសាំង Novavax?

វ៉ាក់សាំង Novavax ដែលត្រូវបានអនុញ្ញាតដោយ Food and Drug Administration (FDA, រដ្ឋបាលចំណីអាហារ និង ឱសថ) ថ្មីបំផុតមានភាពខុសគ្នាពីវ៉ាក់សាំងជំងឺ COVID-19 ផ្សេងទៀតដែលមានផ្តល់ជូនបច្ចុប្បន្ននៅសហរដ្ឋអាមេរិក។ Novavax គឺជាវ៉ាក់សាំងប្រភេទរងនៃប្រូតេអ៊ីនដែលប្រើបច្ចេកវិទ្យាដូចគ្នានឹងវ៉ាក់សាំងដែលត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយជាយូរណាស់មកហើយ ដូចជា HPV, ជំងឺរលាកថ្លើមប្រភេទ B និងផ្តាសាយធំជាដើម។ Novavax គឺជាស៊េរីមាន 2 ដូសដែលចាក់មុនក្រោយ គ្នា 21 ថ្ងៃសម្រាប់បុគ្គលដែលមានអាយុ 12 ឆ្នាំឡើង ទៅ។

## Novavax គឺជាវ៉ាក់សាំងប្រភេទរងនៃប្រូតេអ៊ីនែបបចាស់

ខណៈវ៉ាក់សាំងដែលត្រូវបានអនុញ្ញាតនីមួយៗមានប្រសិទ្ធភាពក្នុងការជួយឱ្យប្រព័ន្ធភាពស៊ាំរបស់រាងកាយយើងស្គាល់ និងវាយប្រហារវីរុស COVID-19 វ៉ាក់សាំង Novavax ប្រើបច្ចេកវិទ្យាវ៉ាក់សាំងបែបចាស់ជាង ដែលយើងស្គាល់ច្រើនជាង។



- វ៉ាក់សាំងប្រភេទរងនៃប្រូតេអ៊ីនសម្រាប់ជំងឺ COVID-19 មានបំណែក (ប្រូតេអ៊ីន) នៃវីរុសដែលបង្កជំងឺ COVID-19
- វ៉ាក់សាំងនេះក៏មានសារធាតុបន្ថែមរួមជាមួយជាតិខ្លាញ់ និងជាតិស្ករ ដើម្បីជួយឱ្យប្រព័ន្ធភាពស៊ាំប្រតិកម្មនឹងវីរុស និងការពារអ្នកនាពេលអនាគត
- វាមិនមាន mRNA ទេ

## វ៉ាក់សាំង Novavax ត្រូវបានបង្ហាញថាមានផលប៉ះពាល់តិចតួចបំផុត

ផលប៉ះពាល់បណ្តោះអាសន្នរបស់វ៉ាក់សាំង Novavax មិនខុសគ្នាពីផលប៉ះពាល់ដែលកើតមានជាធម្មតាពីវ៉ាក់សាំងជំងឺ COVID-19 ផ្សេងទៀតទេ។ ឈឺចុកចាប់/ឈឺខ្លួនឡើងក្រហមនិងហើមនៅកន្លែងចាក់ថ្នាំ ក៏ដូចជាអស់កម្លាំងខ្លាំង ឈឺសាច់ដុំ ឈឺក្បាល ឈឺសន្លាក់ ចង្អោរ/ក្អួត និងគ្រុនក្តៅ។ វ៉ាក់សាំងប្រភេទរងនៃប្រូតេអ៊ីនសម្រាប់ជំងឺ COVID-19 មិនអាចបង្កជំងឺ COVID-19 ឬជំងឺផ្សេងទៀតទេ។

## តើទិន្នន័យបង្ហាញអំពីអ្វី?

ការពិសោធសាកល្បងវេជ្ជសាស្ត្រដែលធ្វើឡើងនៅរដូវផ្ការីកឆ្នាំ 2021 បានបង្ហាញថាវ៉ាក់សាំង Novavax មានប្រសិទ្ធភាព 90% ក្នុងការបញ្ឈប់ការចម្លងជំងឺ COVID-19 និងមានប្រសិទ្ធភាព 100% ក្នុងការបង្ការកុំឱ្យស្លាប់ពាក់ព័ន្ធនឹងជំងឺ COVID-19។

យោងតាមការពិសោធជាបន្តបន្ទាប់ គេបានលើកឡើងថាវ៉ាក់សាំងនេះបានជំរុញឱ្យភាពស៊ាំមានប្រតិកម្មខ្លាំងប្រឆាំងនឹងវីរុសបំប្លែងខ្លួនទាំងអស់នៃជំងឺ COVID-19 រួមទាំង BA.5 ផងដែរ ។ វ៉ាក់សាំងប្រភេទរងដូចជា Novavax មិនប្រើវីរុសរស់ និងមិនអាចផ្លាស់ប្តូរ ឬជះឥទ្ធិពលដល់ហ្សែនរបស់យើងទេ។ យើងក៏បានដឹងដែរថាវ៉ាក់សាំង Novavax៖



- ត្រូវបានប្រើយ៉ាងមានប្រសិទ្ធភាពក្នុងប្រទេសផ្សេងទៀតជាច្រើន រួមទាំងកាណាដាផងដែរតាំងពីឆ្នាំ 2021
- មិនមានសារធាតុផ្សំដូចក្នុងវ៉ាក់សាំងផ្សេងទៀតដែលបង្កអាលែកហ្ស៊ីទេ
- ប្រើបច្ចេកវិទ្យាស្រដៀងគ្នាដែលប្រើក្នុងវ៉ាក់សាំងពេញនិយមដូចជា ផ្តាសាយធំ, HPV, ជំងឺរលាកថ្លើមប្រភេទ B និងរើមជាដើម

វ៉ាក់សាំង Novavax បានឆ្លងកាត់ដំណើរការ Emergency Use Authorization (EUA, ការផ្តល់សិទ្ធិអនុញ្ញាតឱ្យប្រើប្រាស់ក្នុងពេលមានអាសន្ន) របស់ FDA នឹងជាជម្រើសដែលមានសុពលភាព ជាពិសេសសម្រាប់បុគ្គលដែលត្រូវការជម្រើសផ្សេងពីវ៉ាក់សាំង mRNA។

កម្រិតថ្នាំបន្ថែមអាចត្រូវបានណែនាំសម្រាប់ក្រុមមនុស្សផ្សេងទៀត។

## វ៉ាក់សាំងនៅតែជាជម្រើសល្អបំផុត

ខណៈដែលជំងឺ COVID-19 បន្តកើតមាន ជម្រើសវ៉ាក់សាំងមានកាន់តែច្រើន។ អ្វីដែលសំខាន់គឺត្រូវចងចាំថា ការចាក់វ៉ាក់សាំងគឺប្រសើរបំផុត។ មិនថាជាវ៉ាក់សាំងម៉ាកអ្វីទេ វ៉ាក់សាំងគឺជាការការពារល្អបំផុតពីជំងឺ COVID-19 និងផលប៉ះពាល់របស់វា។ សូមពិគ្រោះជាមួយអ្នកផ្តល់សេវាថែទាំអំពីជម្រើសល្អបំផុតសម្រាប់អ្នក។

Washington State Department of Health

DOH 825–052 **August** 2022 Khmer
ដើម្បីស្នើសុំឯកសារនេះជាទម្រង់ផ្សេងទៀត សូមហៅទូរសព្ទមកលេខ 800-525-0127។ អតិថិជនដែលពិការត្រចៀកឬស្តាប់មិនសូវឮ សូមទូរសព្ទទៅលេខ 711 (Washington Relay) ឬផ្ញើអ៊ីមែលទៅ civil.rights@doh.wa.gov។